ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ: ៤៣៥៩ សជណ.អក.មអជ

ថ្ងៃ សុក្រ ០៤ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា៖ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញឲ្យមានសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ដោយជួយឲ្យប្រជាពលរដ្ឋនៅតំបន់ជនបទបានទទួលអគ្គិសនីប្រើប្រាស់សម្រាប់សេដ្ឋកិច្ច សង្គម និងលំនៅដ្ឋាន រួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញលើកទឹកចិត្តផ្នែកឯកជនឲ្យចូលរួមវិនិយោគធ្វើសេវាកម្មអគ្គិសនីនៅជនបទប្រកបដោយចីរភាព **អគ្គិសនីកម្ពុជា** បន្តផ្តល់ថវិកាជាអំណោយដល់នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (ហៅកាត់ថា "ម.អ.ជ.") ដើម្បីបន្តអនុវត្តន៍ **"កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ"**។ កម្មវិធីនេះ ជាកម្មវិធីអនុវត្តន៍ពីឆ្នាំ២០១៣ និងបន្តអនុវត្តន៍ក្នុងឆ្នាំ២០២០។ គោលបំណងនៃកម្មវិធី គឺជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាលដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ កម្មវិធីនេះ បានជួយដល់គ្រួសារជនបទទទួលបាននូវផលប្រយោជន៍ច្រើន ដោយ ម.អ.ជ. បានផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិក ក្នុង១ប្រព័ន្ធ ដល់គ្រួសារជនបទដែលបានទិញប្រព័ន្ធយកទៅប្រើប្រាស់ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធមួយផ្នែក ហើយអ្នកទិញត្រូវបានអនុគ្រោះឲ្យសងរំលស់ថ្លៃនៅសល់ពីការឧបត្ថម្ភធនមក ម.អ.ជ. វិញ ក្នុងរយៈពេល ៤ឆ្នាំ។ ការផ្តល់ការអនុគ្រោះនេះ មានគោលបំណងជួយគ្រួសារជនបទឲ្យទទួលបានអគ្គិសនីប្រើប្រាស់ពីការផ្គត់ផ្គង់ថាមពលមួយប្រកបដោយសុវត្ថិភាព និងបង្កើនជីវភាពរស់នៅឲ្យប្រសើរឡើង ព្រមទាំងទទួលបាននូវថ្លៃអគ្គិសនីថោកជាង បើប្រៀបធៀបជាមួយការប្រើចង្កៀងប្រេងកាត ចង្កៀងម៉ាស៊ូត និងអាគុយជាដើម។ ម.អ.ជ. នឹងតម្លើងប្រព័ន្ធនេះជូនដល់ផ្ទះគ្រួសារជនបទអ្នកទិញ។ ក្រោយពេលសងគ្រប់ចំនួន ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់តារា ទូរស័ព្ទលេខ 015 776-770 / 011 244-246 ឬលោក ជាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 089 776-770 / 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅ ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

ចម្លងជូន៖
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ